# ព្រះរាជក្រឹត្យ

នស/រកត/០២១៨/២១៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥ ចុះថ្ងៃទី ១៧ ខែ មករាឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ និងថ្នាក់តាមអតីតភាពការងារ ជាករណីពិសេស ដល់មន្ត្រីរាជការ ១៥ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួង ស្ថាប័នចំនួន ០៦ ៖

**ក/-ក្រសួងអភិវឌ្ឍន៍ជនបទ**

១- លោកស្រី **ស៊ុ ណារ៉ាឌុង** ពីវរមន្ត្រី ថ្នាក់លេខ ៣ មកឧត្តមមន្ត្រី ថ្នាក់លេខ ៥

២- លោក **សំ នី** ពីវរមន្ត្រី ថ្នាក់លេខ ២ មកឧត្តមមន្ត្រី ថ្នាក់លេខ ៦

៣- លោក **តាន់ ឆាសនា** ពីវរមន្ត្រី ថ្នាក់លេខ ៣ មកឧត្តមមន្ត្រី ថ្នាក់លេខ ៦

៤- លោក **ហ៊ឺ សុរិន** ពីវរមន្ត្រី ថ្នាក់លេខ ៣ មកឧត្តមមន្ត្រី ថ្នាក់លេខ ៦

៥- លោក **ជា យុទ្ធារុណា** ពីវរមន្ត្រី ថ្នាក់លេខ ៣ មកឧត្តមមន្ត្រី ថ្នាក់លេខ ៦

៦- លោក **ឡុង ឌុន្នី** ពីវរមន្ត្រី ថ្នាក់លេខ ៣ មកឧត្តមមន្ត្រី ថ្នាក់លេខ ៦

**ខ/-ក្រសួងមុខងារសាធារណៈ**

១-លោកស្រី **ពេជ្រ ម៉ុនធិនបុប្ផាច័ន្ទ** ពីវរមន្ត្រី ថ្នាក់លេខ ៣ មកឧត្តមមន្ត្រី ថ្នាក់លេខ ៦

២- លោក **ឃឹម ម៉ុនលីន** ពីអនុមន្ត្រី ថ្នាក់លេខ ២ មកឧត្តមមន្ត្រី ថ្នាក់លេខ ៦

**គ/-ក្រសួងធម្មការ និងសាសនា**

១- លោក **មុំ ច័ន្ទតារា** ពីវរមន្ត្រី ថ្នាក់លេខ ១ មកឧត្តមមន្ត្រី ថ្នាក់លេខ ៥

**ឃ/-ទីស្តីការគណៈរដ្ឋមន្ត្រី**

១- ឯកឧត្តម **ម៉ក់ សម្បត្តិ** ពីវរមន្ត្រី ថ្នាក់លេខ ៣ មកឧត្តមមន្ត្រី ថ្នាក់លេខ ៤

**ង/-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- ឯកឧត្តម **យ៉ោក សុទ្ធី** ពីវរមន្ត្រី ថ្នាក់លេខ ១ មកឧត្តមមន្ត្រី ថ្នាក់លេខ ៣

**ច/-ក្រសួងពាណិជ្ជកម្ម**

១- លោកស្រី **សោម សុផា** ពីវរមន្ត្រី ថ្នាក់លេខ ១ មកឧត្តមមន្ត្រី ថ្នាក់លេខ ២

២- ឯកឧត្តម **ផាន អូន** ពីវរមន្ត្រី ថ្នាក់លេខ ២ មកឧត្តមមន្ត្រី ថ្នាក់លេខ ៥

**ឆ/-ក្រសួងកិច្ចការនារី**

១- លោកជំទាវ **ម៉ុនឈិត ឆាសនា** ពីវរមន្ត្រី ថ្នាក់លេខ ១ មកឧត្តមមន្ត្រី ថ្នាក់លេខ ៥

២- លោកស្រី **ចាន់ សុធាវី** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកឧត្តមមន្ត្រី ថ្នាក់លេខ ៥

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣.៧. ១៨០២.១១៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៨*

លេខៈ ១៣៩ ស.ណ

**សំណៅចម្លងមានតម្លៃជាការចែកផ្សាយ**

ថ្ងៃព្រហស្បតិ៍ ៨រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**